ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ: ០៥៣/១៥ ក.អ.ជ.ប្រក

ថ្ងៃ សុក្រ ៧កើត ខែ ពិសាខ ឆ្នាំមមែ ព.ស. ២៥៥៩

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា គ.ស. ២០១៥

# ប្រកាស

## ស្តីពីការកែសម្រួលមន្ត្រីរាជការបំពេញការងារនៅអង្គភាពអនុវត្តន៍គម្រោងឥណទាន ក្រសួងអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងប្រកាសលេខ ១៥៧/១៤ ក.អ.ជ.ប្រក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៤ របស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងឥណទានជនបទនៃក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមការងារចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

## សម្រេច

**ប្រការ ១.-** តែងតាំងមន្ត្រីរាជការសម្រាប់បំពេញការងារនៅអង្គភាពអនុវត្តន៍គម្រោងឥណទានក្រសួងអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម÷

១. លោកស្រី **ច័ន្ទ បូរ៉ានី** ជាប្រធានអង្គភាព ជំនួសលោក **ស៊ីម រដ្ឋា** ដែលត្រូវបានទទួលភារកិច្ចថ្មី

២. លោកស្រី **ស៊ីម ពៅរតនាមុនី** ជាមន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ ជំនួស លោកស្រី **ច័ន្ទ បូរ៉ានី**

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

៣. កញ្ញា **ម៉ិន ន័ងា** ជាភ្នាក់ងារឥណទានប្រចាំស្រុកបាណន់ និងស្រុកថ្មគោល

**ប្រការ ២.-** រាល់សេចក្តីសម្រេចទាំងឡាយ ដែលផ្ទុយនឹងខ្លឹមសារនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣.-** នាយកខុទ្ទកាល័យ គណៈកម្មការគ្រប់គ្រងគម្រោងឥណទានជនបទ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេស អគ្គាធិការ ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង និងសាមីជនដែលរាយនាមក្នុងប្រការ ១ មានភារកិច្ចអនុវត្តតាមប្រកាសនេះ ឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ព្រះរាជាណាចក្រកម្ពុជា ក្រសួងអភិវឌ្ឍន៍ជនបទ

**ជា សុផារ៉ា**

<u>**កន្លែងទទួល÷**</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
- សាលាខេត្តបាត់ដំបង
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ ៣
  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ